ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

លេខ:...០៥៣.....បទ..ឬក.......

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការ ដឹកនាំរៀបចំដំណើរការប្រឡងប្រជែងជ្រើសរើស បេក្ខជន-បេក្ខនារី ឱ្យចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន

## រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងឥស្សរជន ជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២០០ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍ និងទូរគមានគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញសេចក្តីជូនដំណឹងលេខ ០៤១ បទ ស.ជ.ណ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការប្រឡងធ្វើតេស្តចូលរៀន ជំនាញវិជ្ជាជីវៈបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- យោងតាមការងារចាំបាច់ របស់វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

## សម្រេច

**ប្រការ ១**.-

ត្រូវបានបង្កើតគណៈកម្មការដឹកនាំ រៀបចំដំណើរការប្រឡងប្រជែង ជ្រើសរើស បេក្ខជន-បេក្ខនារី ឱ្យចូលរៀន វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT Professional) នៅវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ខូវ មករា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម | **សេង សុភាព** | ប្រធានវិទ្យាស្ថាន | អនុប្រធាន |
| ៣- លោក | **សេង សុទ្ធី** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៤- លោក | **ឆាយ ថៃ** | អនុប្រធានវិទ្យាស្ថាន | លេខាធិការ |

**ប្រការ ២ .-**

គណៈកម្មការដូចមានចែងក្នុងប្រការ១ខាងលើមាន អនុគណៈកម្មការចំនួន០៥ ជាជំនួយការដើម្បីដំណើរការប្រឡងប្រជែងជ្រើសរើស បេក្ខជន-បេក្ខនារី ឱ្យចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដូចមានរាយនាមខាងក្រោម៖

**១. អនុគណៈកម្មការ កណ្តាល**
**២. អនុគណៈកម្មការ ទទួលពាក្យប្រឡងជ្រើសរើស**
**៣. អនុគណៈកម្មការ គណៈមេប្រយោគ**
**៤. អនុគណៈកម្មការ អនុរក្ស និងត្រួតពិនិត្យតាមបន្ទប់**
**៥. អនុគណៈកម្មការសន្តិសុខ**

**ប្រការ ៣ .-**

អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងគ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួង និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

ប្រាក់_សុខុន

**កន្លែងទទួលៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ដូចប្រការ៣ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ